# សេចក្តីសង្ខេប

| | | |
|---|---|---|
| **កម្មវិធីវិនិយោគព្រៃឈើ<br>សេចក្តីសង្ខេបនៃគម្រោងសំណើផែនការវិនិយោគព្រៃឈើកម្ពុជា** | | |
| **ប្រទេស/តំបន់** | កម្ពុជា | |
| **ថវិការក្នុងការស្នើនូវពីកម្មវិធីវិនិយោគព្រៃឈើ(ដុល្លា)** | **ប្រាក់កម្ចី:** TBD | **ជំនួយ**: ២៤ លានដុល្លាអាមេរិក |
| **មន្រ្តីបង្គោល(កម្ពុជា)** | លោកបណ្ឌិត **ឃុន សាវ៉េត**<br>ប្រធាននាយកដ្ឋានសត្វព្រៃ និងជីវចម្រុះនៃរដ្ឋបាលព្រៃឈើ<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |
| **ស្ថាប័នជាតិក្នុងការអនុវត្តគម្រោង** | រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>អគ្គនាយកដ្ឋានរដ្ឋបាល ការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន | |
| **ការចូលរួមពីធនាគារអភិវឌ្ឍន៍ចម្រុះ** | ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) និងធនាគារពិភពលោក(WB) | |
| **មន្រ្តីបង្គោលពីធនាគារអភិវឌ្ឍន៍ចម្រុះ** | **Ancha Srinivasan**<br>អ្នកជំនាញការផ្នែកអាកាសធាតុ<br>asrinivasan@adb.org | TBD |
| MDB FIP TTLs. | **Mr. Bruce Dunn, ADB**<br>អ្នកជំនាញការផ្នែកបរិស្ថាន<br>bdunn@adb.org | **Mr. Robert R. Davis**<br>អ្នកជំនាញការផ្នែកព្រៃឈើជាន់ខ្ពស់<br>rdavis1@worldbank.org |

## ការពិពណ៌នាអំពីផែនការវិនិយោគ

### ក. ឧបសគ្គនានាដែលទាក់ទងនឹងការអនុវត្តរេដបូកនៅប្រទេសកម្ពុជា

១. ប្រទេសកម្ពុជាបានសម្រេចបាននូវកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ ប៉ុន្តែ ក៏មានផលប៉ះពាល់ជាអវិជ្ជមានមកលើធនធានធម្មជាតិ រួមទាំងព្រៃឈើផងដែរ។ បុព្វហេតុសំខាន់ៗដែលបណ្តាលអោយមានការបាត់បង់និងរេចរឹលព្រៃឈើជាប់ពាក់ព័ន្ធដោយកត្តាជាច្រើនក្រៅពីវិស័យព្រៃឈើ។ ការផ្តល់ដីសម្រាប់សម្បទានសេដ្ឋកិច្ចក្នុងការពង្រីកនៃការវិនិយោគវិស័យកសិកម្ម និងសម្បទានដីសង្គមកិច្ចសម្រាប់ប្រជាជនក្រីក្រនិងគ្រួសារដែលខ្វះខាតដីធ្លីមានឥទ្ធិពលអវិជ្ជមានដល់ធនធានព្រៃឈើ។ ភាពទន់ខ្សោយអភិបាលកិច្ចព្រៃឈើនិងការអនុវត្តច្បាប់ភូមិបាល រួមទាំងភាពខ្វះខាតនៃការចុះបញ្ជីដីរដ្ឋ និងការកំណត់ព្រំប្រទល់ដីព្រៃឈើ បន្ថែមឥទ្ធិពលអវិជ្ជមានដល់ធនធានព្រៃឈើ និងការរុករាដីព្រៃឈើ និងការកាប់ឈើដោយមិនមានការអនុញ្ញាត្តិ និងការប្រមូលផលឈើ និងអនុផលព្រៃឈើដោយគ្មានចីរភាព។ ការថយចុះបរិមាណឈើផ្គត់ផ្គង់ដែលមានប្រភពមកពីការសំអាតដីព្រៃឈើ និងកត្តាជម្រុញ ដែលមានឥទ្ធិពលអវិជ្ជមានលើការវិនិយោគក្នុងវិស័យការគ្រប់គ្រងព្រៃឈើប្រកបដោយចីរន្តរភាព និងបានបង្កើតអោយមានភាពខ្វះចន្លោះរវាង ការផ្គត់ផ្គង់ និងការប្រើប្រាស់ ដែល

អាចរំពឹងថានឹងមានការកើនឡើងនូវសំពាធនូវការប្រើប្រាស់ធនធានក្នុងតំបន់ការពារធម្មជាតិ ប្រសិនបើគ្មានកិច្ចផ្តួចផ្តើមណាមួយកើតឡើងទេនោះ។

២. កំណែទម្រង់ក្នុងវិស័យព្រៃឈើក្នុងឆ្នាំ២០១៦ និងឆ្នាំ២០១៧ បានបង្វែតំបន់ព្រៃការពារ រួមទាំងតំបន់គ្រប់គ្រងអភិរក្សរបៀងជីវចម្រុះ ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អោយស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ចំពោះសម្បទានដីសេដ្ឋកិច្ចដែលពីមុនគ្រប់គ្រងដោយក្រសួងបរិស្ថានត្រូវបានផ្ទេរអោយស្ថិតក្រោមការគ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ផ្ទៃដីច្រើនជាង៤លានហិកតាត្រូវបានផ្ទេររវាងក្រសួងទាំងពីរ។ ការចុះបញ្ជី និងការកំណត់ព្រំប្រទល់នៅទីវាលនៅមិនទាន់បានអនុវត្តនៅឡើយ។ ប្រព័ន្ធរដ្ឋបាល កំពុងស្ថិតក្នុងដំណើការកែសម្រួលពីនិតិវិធីក្នុងការគ្រប់គ្រងតំបន់ទាំងនេះ ប៉ុន្តែជាមួយតម្រូវការជាក់ស្តែងគឺ គេត្រូវការបុគ្គលិកបន្ថែមកម្មវិធីបណ្តុះបណ្តាល និងការកសាងសមត្ថភាពព្រមទាំង ការគាំទ្រផ្នែកហេដ្ឋារចនាសម្ព័ន្ធជារូបវ័ន្តនៅកម្រិតមូលដ្ឋាន។ តំបន់ការពារធម្មជាតិទាំងអស់គឺតត្រូវការជាចាំចាច់នូវផែនការគ្រប់គ្រង គឺមានតែតំបន់ការពារធម្មជាតិមួយក្នុងចំណោមតំបន់ការពារធម្មជាតិចំនួន៥៤ ដែលបានបែងចែកតំបន់គ្រប់គ្រងដោយផ្អែកលើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។ ជាមួយនឹងដំណើរកែទម្រង់ការគ្រប់គ្រងតាមវិមជ្ឍការបានបង្កើតជាស្ថានការដែលជាឧសគ្គសម្រាប់ឆ្នាំខាងមុខ។

## ខ. វិស័យ ផ្នែក និងតំបន់នៃការអន្តរាគមន៍

៣. កម្មវិធីវិនិយោគព្រៃឈើ/ផែនការវិនិយោគព្រៃឈើ មានគោលបំណងក្នុងការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងផ្នែកចំនួន០៣។ គោលដៅរួមសម្រាប់គម្រោងទាំងបីគឺ មានគោលបំណងគាំទ្រស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងគម្រោងចំនួនបី។ ជារួមគម្រោងចំនួនបី នឹងគាំស្ថាប័នរាជរដ្ឋាភិបាលកម្ពុជាកំណត់ និងរៀបចំតួនាទីរបស់ថ្មីពួកគេ។ ក្រសួងបរិស្ថានផ្តោតលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ(គម្រោទី១) និងរដ្ឋបាលព្រៃឈើ ផ្តោតលើការគ្រប់គ្រងព្រៃផ្តល់ផល (គម្រោងទី២) និងជាចុងក្រោយគម្រោងគាំទ្រថ្នាក់ជាតិ គឺដើម្បីគាំទ្រការប្រមូលប្រព័ន្ធព័ត៌មានស្តីពីព្រៃឈើដែលជាតម្រូវសម្រាប់ការរៀបចំគោលនយោបាយទាក់ទងនឹងការអនុវត្តរេដបូក និងគោលនយោបាយព្រៃឈើជាទូទៅ(គម្រោងទី៣)។គម្រោងទាំងបីមានភាពស្របគ្នាជាមួយយុទ្ធសាសស្រ្តរេដបូកជាតិ និងចូលរួមចំណែកក្នុងការសម្រេចអោយបានការអនុវត្តផែនការជាតិក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

៤. **គម្រោងទី១៖** ការគ្រប់គ្រងតំបន់ទេសភាពដោះស្រាយការប្រែប្រួលអាកាសធាតុ និងភ្ជាប់តំបន់អភិរក្សរបៀងជីវចម្រុះនឹងគាំទ្ររាជរដ្ឋាភិបាលកម្ពុជា (១)ពង្រឹងដល់ការអភិរក្សនិងការគ្រប់គ្រងព្រៃឈើ រួមបញ្ចូលអ្នកពាក់ព័ន្ធនានា និងកិច្ចផ្តួចផ្តើមក្នុងការដោះស្រាយនូវបញ្ហាអាទិភាព (២)លើកកម្ពស់ដល់ការគ្រប់គ្រងអេកូស៊ីស្ទឹមភ្ជាប់តំបន់អភិរក្សរបៀង នឹងភ្ជាប់ជាមួយអ្នកពាក់ព័ន្ធនានាក្នុងការគ្រប់គ្រង (៣)ធ្វើអោយប្រសើឡើងនូវជីវភាពរស់របស់សហាគមន៍ជនបទ និង(៤) កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ពីវិស័យព្រៃឈើ។ គម្រោងនឹងរួមបញ្ចូលសកម្មភាពការគ្រប់គ្រងតំបន់

ទេសភាពការសាកល្បងគម្រូដើម្បីពង្រឹង និងគ្រប់គ្រងតំបន់អភិរក្សរបៀងដែលទើបតែបានរៀបចំដោយរាជរដ្ឋាភិបាលនាពេលថ្មីនេះ។

៥. **គម្រោងទី២៖** ការស្តារព្រៃឈើ និងផលិតកម្មព្រៃឈើតាមរយៈការធ្វើការជាដៃគូរវាងឯកជននិងសាធារណៈ។ គម្រោងនេះនឹងគាំទ្ររាជរដ្ឋាភិបាលដើម្បីបង្កើតលក្ខខណ្ឌសមស្របសម្រាប់ការវិនិយោគក្នុងវិស័យព្រៃឈើ បង្កើនផលិតកម្មព្រៃឈើ និងដើម្បីបំពេញតម្រូវការឈើ និងឈើថាមពលនាពេលអនាគត។ គម្រោងនេះនឹងរួមបញ្ចូលការចូលរួមពីវិស័យឯកជនរួមទាំងផ្តល់ឱកាសសម្រាប់សហគមន៍ដើម្បីធ្វើអោយប្រសើឡើងនូវជីវភាពរបស់ពួកគេតាមរយៈ ការធ្វើកសិដ្ឋាន និងសកម្មភាពដែលទាក់ទងនិងព្រៃឈើ សកម្មភាពទាំងនេះរួមទាំង ការបង្កើតផលិតកម្មព្រៃឈើ និងភ្ជាប់ទៅនឹងទីផ្សារនៃផលិតផលឈើ និងឈើថាមពលទាំងនោះ។

៦. **គម្រោងទី៣៖** ការអនុវត្តប្រព័ន្ធត្រួតពិនិត្រព្រៃឈើ នឹងគាំដល់ការអនុវត្តដល់ការអនុវត្តសារពើភណ្ឌព្រៃឈើជាតិ ដែលជាផ្នែកមួយនៃប្រព័ន្ធត្រួតពិនិត្រព្រៃឈើជាតិ។ គម្រោងនេះនឹងជួយកសាងដល់សកម្មភាពដែលមានស្រាប់ និងភ្ជាប់ស្ថាប័នទាំងបីដែលទទួលបន្ទុកក្នុងការគ្រប់គ្រងដីព្រៃឈើដូចជា រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានរដ្ឋបាលកាពារនិងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន។ ប្រព័ន្ធព័ត៌មាននឹងអនុញ្ញាត្តិអោយប្រទេសកម្ពុជាដើម្បីប្រមូលព័ត៌មានស្តីពីព្រៃឈើរបស់រដ្ឋ រួមទាំងព័ត៌មានស្តីពីសមាសភាពទាំងប្រាំពីរនៃការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងធ្វើអោយប្រសើឡើងនូវប្រព័ន្ធរាការណ៍សម្រាប់ដល់ ក្របខណ្ឌអនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ព្រមទាំង ការរាយកាណ៍អន្តរជាតិដែលជាការប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះ អនុសញ្ញា CBD UNFF, FAO FRA, CITES, RAMSAR etc។ សមាសភាពទីពីរ និងសមាសភាពទីបី នឹងដោះស្រាយតម្រូវការព័ត៌មានសម្រាប់ការត្រួតពិនិត្យសម្បទានដីសេដ្ឋកិច្ច និងការប្រើប្រាស់ដីផ្សេងៗទៀត និងសាកល្បង អនុវត្តប្រព័ន្ធត្រួតពិនិត្យចរាចរឈើស្របច្បាប់ ជាលក្ខខណ្ឌអំណោយផលសម្រាប់ការវិនិយោគក្នុងវិស័យព្រៃឈើ។

៧. សមាសភាពនៃគម្រោងទាំងបី នឹងគូសបង្ហាញនូវការអភិវឌ្ឍន៍ប្រកបដោយចីរភាព ការគ្រប់គ្រងនិងការប្រើប្រាស់ធនធានធម្មជាតិ ព្រមទាំងកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងពង្រឹងភាពធននឹងការប្រែប្រួលអាកាសធាតុ។

## លទ្ធផលរំពឹងទុក

៨. កម្មវិធីវិនិយោគព្រៃឈើ សម្រាប់កម្ពុជានឹងដោះស្រាយឧបសគ្គសំខាន់មួយចំនួនៗដើម្បីការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព កិច្ចខិតខំប្រឹងប្រែងដើម្បីបន្ធូបន្ថយ ព្រមទាំងបន្សាំការប្រែប្រួលអាកាសធាតុ និងបង្កើនការចូលរួមផ្នែកព្រៃឈើ ដែលជាប្រយោជន៍ដល់សេដ្ឋកិច្ច បរិស្ថាន និងសង្គមសម្រាប់ប្រទេសជាតិទាំងមូល។ ការកែទម្រង់អភិបាលកិច្ចបរិស្ថានបច្ចុប្បន្នមានន័ថាគម្រោងនឹងមានគោលបំណងអោយមានការផ្លាស់ប្តូរដោយវិជ្ជមាន និងការគាំទ្រដល់រាជរដ្ឋាភិបាលដើម្បីបំពេញតួនាទីថ្មីរបស់ពួកគេ។ គម្រោងទី១ និងទី២ អាចពង្រីកវិសាលភាពអនុវត្តក្នុងតំបន់ដ៏ទៃទៀតនៅក្នុងប្រទេសកម្ពុជា និងមានដើតួនាទីជាគម្រោងអនុវត្តគម្រូក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងផលិតកម្មព្រៃឈើ។

១០.ផលប្រយោជន៍ដែលរំពឹងទុក នឹងរួមបញ្ចូលទាំង ការធ្វើអោយប្រសើឡើងនូវសមត្ថភាពអភិបាលកិច្ច និងមានការគ្រប់គ្រងដី និងព្រៃឈើប្រកបដោយចីរភាព។ គម្រោងនឹងរួមបញ្ចូលទាំងការពង្រឹងសមត្ថភាព សម្រាប់ការធ្វើផែនការប្រើប្រាស់ដីដោយមានការចូលរួម លើកកម្ពស់ភាពច្បាស់លាស់លើការកម្មសិទ្ធដីធ្លីសម្រាប់សហគមន៍ និងការសម្របសម្រួលការវិនិយោគក្នុងការលើកកម្ពស់ជីវភាពដែលដោះស្រាយការប្រែប្រួលអាសជាតុប្រកបដោយចីរភាព។ ការផ្លាស់ប្តូរជាវិជ្ជមាននឹងជះឥទ្ធិពលដល់កម្រិតចំនួនបី៖ រដ្ឋាភិបាល(ថ្នាក់ជាតិ ខេត្ត និងឃុំ) នឹងបង្កើនសមត្ថភាពដើម្បីគ្រប់គ្រងព្រៃឈើក្នុងតំបន់ទេសភាពដើម្បីផ្តល់ប្រយជន៍ចម្រុះ ការវិនិយោគពីវិស័យឯកជននឹងទទួលបានលក្ខខណ្ឌសមប្រកប និងវិនិយោគក្នុងវិស័យផលិតកម្មព្រៃឈើ ដើម្បីកាត់បន្ថយភាពខ្វះចន្លោះពីតម្រូវការ និងការផ្គត់ផ្គង់ និងសហគមន៍មូលដ្ឋាននឹងត្រូវបានធានាសិទ្ធគ្រប់គ្រងលើដីធ្លីរបស់គេ ធ្វើអោយប្រសើឡើងនូវជីវភាព និងមានការចូលរួមក្នុងសកម្មភាពពាណិជ្ជកម្ម ឧទាហរណ៍កសិកម្ម ព្រៃឈើ ទេសចរម្មជាតិ ដើម្បីពង្រឹងប្រាក់ចំណូលរបស់ពួកគេ។

១១. កម្មវិធីវិនិយោគព្រៃឈើនឹងផ្តល់ឱកាសបន្ថែមចំនួនបីដើម្បីអោយមានការផ្លាស់ប្តូរជាវិជ្ជមាន៖

A. ផែនការប្រើប្រាស់ដីដោយមានការចូលរួមសម្រាប់តំបន់ការពារធម្មជាតិ រួមទាំង តំបន់អភិរក្សជីវចម្រុះរបៀង និងធ្វើអោយប្រសើឡើងនូវជីវភាពសម្រាប់ប្រជាជនដែលពឹងអាស្រ័យលើព្រៃឈើដែលកំពុងរស់នៅក្នុង និងជុំវិញតំបន់ការពារធម្មជាតិ។
B. លក្ខខណ្ឌសមប្រកបសម្រាប់ការវិនិយោគជាមួយនឹងគោលបំណងដើម្បីបង្កើនការផ្គត់ផ្គង់ឈើថាមពល និងការផលិតផលិតផលឈើខ្នាតតូច បង្កើតមុខរបរ និងលទ្ធភាពបង្កើតប្រាក់ចំណូលសម្រាប់សហគមន៍មូលដ្ឋាន។
C. លទ្ធភាពអាចទទួលបានព័ត៌មានស្តីពីព្រៃឈើ ដើម្បីរៀបចំគោលនយោបាយ សម្រាប់ព្រៃឈើ និងអនុញ្ញាត្តិអោយកម្ពុជាពង្រីកវិសាលភាពដោះស្រាយលើពីការបាត់បង់ព្រៃឈើក្រោមការអនុវត្តយន្តការរេដបូកដោយយោងតាមសម្រេចរបស់អនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) និងធ្វើអោយប្រសើឡើងនូវការរាយការណ៍សម្រាប់ការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលចេញមកពីការបាត់បង់ព្រៃឈើ និងការស្រូបឧស្ម័នផ្ទះកញ្ចក់ពីបរិយាកាសទៅកាន់ អនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។

១០. កម្មវិធីវិនិយោគព្រៃឈើ នឹងធ្វើការកម្រិតមូលដ្ឋាន និងថ្នាក់ជាតិ និងអនុវត្តសាកល្បងវិធីសាស្រ្តថ្មីៗក្នុងគ្រប់គ្រងធនធានធម្មជាតិដែលជួយដោះស្រាយមូលហេតុនៃការបាត់បង់ និងរេចរឹលព្រៃឈើ និងគាំទ្រដល់ការអនុវត្តយុទ្ធសាស្រ្តដែលជាអាទីភាពក្នុងយុទ្ធសាស្រ្តរេដបូកជាតិ។

## គម្រោងថវិកាចំណាយ

គម្រោងថវិកាដែលស្នើឡើងដែលស្ថិតក្រោមផែនការវិនិយោគព្រៃឈើ៖

| **ឈ្មោះគម្រោង** | **ធានាគារអភិវឌ្ឍនចម្រុះ** | **ថវិកាស្នើសុំ ដល់កម្មវិធីវិនិយោគព្រៃឈើ (លានដុល្លាសហរដ្ឋអាមេរិក)** | | | **ការវិនិយោគពីវិស័យឯកជន(លានដុល្លាសហរដ្ឋអាមេរិក)** | **ការរំពឹងទុកនៃការរួមចំណែកថវិកានានា (លានដុល្លាសហរដ្ឋអាមេរិក)** | **ថវិកាស្នើសុំសម្រាប់រៀបចំគម្រោងលំអិត (លានដុល្លាសហរដ្ឋអាមេរិក)** |
|---|---|---|---|---|---|---|---|
| | | **កម្ចី[1]** | **ជំនួយ** | **សរុប** | | | |
| ការគ្រប់គ្រង តំបន់ទេសភាពដោះស្រាយការប្រែប្រួលអាកាសធាតុ និងភ្ជាប់តំបន់អភិរក្សរបៀងជីវចម្រុះ | នឹងត្រូវកំណត់ | ០ | ១៤ | ១៤ | | ១៣ រួមបញ្ចូល ២ពីរាជរដ្ឋាភិបាលកម្ពុជា | ០.២៥ |
| ការស្តារព្រៃឈើ និងផលិតកម្មឈើ តាមរយៈការធ្វើការជាដៃគូរវាងវិស័យសាធារណៈ និងឯកជន | នឹងត្រូវកំណត់ | | ៧ | ៧ | នឹងត្រូវកំណត់ | ១៥.៤ រួមបញ្ចូល ៩.៨ ពីការវិនិយោគពីវិស័យឯកជន និង ១.៨ ពីរាជរដ្ឋាភិបាលកម្ពុជា | ០.២៥ |
| ការអនុវត្តការត្រួតពិនិត្យព្រៃឈើជាតិ | នឹងត្រូវកំណត់ | ០ | ៣ | ៣ | | ៣ រួមបញ្ចូល ០.៥ ពីរាជរដ្ឋាភិបាលកម្ពុជា | ០.២៥ |
| | | **០** | **២៤** | **២៤** | | **៣១.៤** | |

[1] ទាំង គម្រោងទី១ និងគម្រោងទី២ អាចជាផ្នែកនៃកម្ចី